**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខ : ០៩ សរ**

## សារាចរ
## ស្ដីពី
## ការរៀបចំក្រុមការងារតាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តយុទ្ធសាស្ត្រ ផែនការអភិវឌ្ឍន៍ និងគោលនយោបាយនានា នៅតាមក្រសួង ស្ថាប័ន

រាជរដ្ឋាភិបាលនីតិកាលទី៧នៃរដ្ឋសភា បានសម្រេចដាក់ឱ្យប្រើនូវយុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១ ក្នុងកិច្ចប្រជុំពេញអង្គលើកដំបូង នាថ្ងៃទី២៤ ខែសីហា ឆ្នាំ២០២៣ ដើម្បីកំណើន ការងារ សមធម៌ ប្រសិទ្ធភាព និងចីរភាព សំដៅកសាងមូលដ្ឋានគ្រឹះឆ្ពោះទៅសម្រេចឱ្យបាននូវចក្ខុវិស័យកម្ពុជា ឆ្នាំ២០៥០។ ឯកសារយុទ្ធសាស្ត្រនេះ ត្រូវបានប្រើប្រាស់ជាឯកសារគោលសម្រាប់ការរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍តាមវិស័យ និងផែនការរបស់ក្រសួង ស្ថាប័ន ដើម្បីធានានូវសង្គតិភាព និងភាពប្រទាក់ក្រឡា ដែលត្រូវបែងចែកជាពីរកម្រិត រួមមាន៖ កម្រិតទី១). ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០២៤-២០២៨ និងកម្រិតទី២). ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍តាមវិស័យ ឬផែនការរបស់ក្រសួង ស្ថាប័ន ក្នុងនោះ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍តាមវិស័យ ឬផែនការរបស់ក្រសួង ស្ថាប័ន ត្រូវរៀបចំឱ្យមានភាពប្រទាក់ក្រឡា និងគ្រប់ជ្រុងជ្រោយ ព្រមទាំងអាចតាមដាន ត្រួតពិនិត្យ និងវាយតម្លៃបាន ដើម្បីគាំទ្រដល់ការសម្រេចឱ្យបាននូវគោលដៅនិងគោលបំណង នៃផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០២៤-២០២៨ និងយុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១។ ក្នុងន័យនេះ ដើម្បីធានាដំណើរការការងារនៃក្រសួង ស្ថាប័ន និងអង្គភាពនានារបស់រាជរដ្ឋាភិបាលលើការអនុវត្តការងារ ដែលចង្អុលបង្ហាញដោយយុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១ សំដៅធានានូវស័ក្តិសិទ្ធិភាព និងប្រសិទ្ធភាពក្នុងការអនុវត្តយុទ្ធសាស្ត្រនេះ រាជរដ្ឋាភិបាលបានដាក់ឱ្យអនុវត្តនូវយន្តការការងារ ចំនួន ៣ (បី) ដូចខាងក្រោម៖

(១). **យន្តការដឹកនាំនិងសម្របសម្រួល៖ ក) រាជរដ្ឋាភិបាល** ដឹកនាំការអនុវត្តយុទ្ធសាស្ត្រជារួម ដោយផ្ដោតលើការតម្រង់ទិសការកែសម្រួលវិធានការគោលនយោបាយនានា និងការដាក់ចេញនូវវិធានការគោលនយោបាយថ្មីៗតាមការចាំបាច់, ខ) **គណៈកម្មាធិការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តយុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១ (គ.យ.ប.)** ដឹកនាំសម្របសម្រួលរួម លើការជំរុញការអនុវត្តកិច្ចការពាក់ព័ន្ធនឹងយុទ្ធសាស្ត្របញ្ចកោណរបស់ក្រុមប្រឹក្សា គណៈកម្មាធិការ ក្រសួង ស្ថាប័ន និង **គ) ក្រសួងផែនការ** ដឹកនាំសម្របសម្រួលកម្រិតបច្ចេកទេសក្នុងការរៀបចំផែនការសកម្មភាព និងសូចនាករសមិទ្ធកម្មគន្លឹះរបស់ក្រសួង ស្ថាប័ន ព្រមទាំងផ្ដល់ផ្គង់ និងតម្រឹមការរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០២៤-២០២៨ និងផែនការសកម្មភាពសម្រាប់ការអភិវឌ្ឍតាមវិស័យ។

**(២). យន្តការអនុវត្ត៖ ក) ក្រសួង ស្ថាប័ន** ជាតួអង្គស្នូលត្រូវបុរេសកម្ម, សកម្ម និងមានកិច្ចសហការជិតស្និទ្ធ ជាមួយគ្រប់ភាគីពាក់ព័ន្ធ ក្នុងការរៀបចំផែនការ, ការអនុវត្ត, ការបូកសរុបវឌ្ឍនភាព និងការវាយតម្លៃ, **ខ) ក្រុមប្រឹក្សា និងគណៈកម្មាធិការអន្តរក្រសួង** ដែលមានសមត្ថកិច្ចពាក់ព័ន្ធ ទទួលបន្ទុកសម្របសម្រួលលើការជំរុញការអនុវត្តការងារអាទិភាពដែលមានចរិតអន្តរក្រសួង-ស្ថាប័ន ឬ អន្តរវិស័យ និង **គ) រដ្ឋបាលថ្នាក់ក្រោមជាតិ** ត្រូវចូលរួមអនុវត្តយុទ្ធសាស្ត្របញ្ចកោណ ព្រមទាំងចូលរួមផ្តល់ធាតុចូលលើការបូកសរុបវឌ្ឍនភាព និងការវាយតម្លៃ។

**(៣). យន្តការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ៖ ក) គ.យ.ប.** ដឹកនាំ ពិនិត្យ និងសម្រេចលើក្របខ័ណ្ឌតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ ដែលផ្អែកលើភស្តុតាង រួមទាំងសូចនាករសមិទ្ធកម្មគន្លឹះ ព្រមទាំងពិនិត្យ និងលើកសំណើជូនប្រមុខរាជរដ្ឋាភិបាល ដើម្បីពិនិត្យ និងសម្រេចលើរបាយការណ៍វឌ្ឍនភាពនៃការអនុវត្ត ព្រមទាំងផ្តល់អនុសាសន៍តម្រង់ទិសកែសម្រួលគោលនយោបាយ, យុទ្ធសាស្ត្រតាមវិស័យ និងយន្តការអនុវត្ត និង **ខ) គ្រប់ក្រសួង ស្ថាប័ន** ត្រូវរៀបចំផែនការ និងគោលការណ៍សម្រាប់ការតាមដាន, ការត្រួតពិនិត្យ និងការវាយតម្លៃផ្ទៃក្នុងរបស់ខ្លួន ព្រមទាំងរៀបចំរបាយការណ៍ប្រចាំឆ្នាំស្តីពីវឌ្ឍនភាពក្នុងការអនុវត្តយុទ្ធសាស្ត្រ។

ឈរលើមូលដ្ឋានខាងលើ សំដៅធានានូវប្រសិទ្ធភាព និងនិរន្តរភាពការងារ, រាជរដ្ឋាភិបាល សូមដាក់ចេញនូវគោលការណ៍ពាក់ព័ន្ធនឹងការរៀបចំក្រុមការងារទទួលបន្ទុកលើកិច្ចការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តយុទ្ធសាស្ត្រ ផែនការអភិវឌ្ឍន៍ និងគោលនយោបាយនានា ហៅកាត់ថា "**ក.យ.ផ.គ.**" នៅតាមក្រសួង ស្ថាប័ន ដូចខាងក្រោម៖

### ក. រចនាសម្ព័ន្ធស្ថាប័ន

ក្រសួង ស្ថាប័ន ត្រូវបង្កើត **ក.យ.ផ.គ.** ប្រចាំក្រសួង ស្ថាប័នសាមី ដែលមានសមាសភាពដូចតទៅ៖

| | | |
|---|---|---|
| - រដ្ឋលេខាធិការ/អនុរដ្ឋលេខាធិការ/អនុប្រធានស្ថាប័ន | | ប្រធាន |
| - អគ្គលេខាធិការ/អគ្គនាយក | ០១ឬច្រើនរូប | អនុប្រធាន |
| - មន្ត្រីជំនាញពាក់ព័ន្ធ | ០១ ឬច្រើនរូប | សមាជិក។ |

ការបង្កើតក្រុមការងារនេះ ត្រូវប្រើប្រាស់ឱ្យអស់លទ្ធភាព និងសក្តានុពលនៃមុខងារ ធនធានហិរញ្ញវត្ថុ និងធនធានមនុស្ស ដែលមានស្រាប់ ដែលស្ថិតក្រោមសមត្ថកិច្ចរបស់ក្រសួង ស្ថាប័នរបស់ខ្លួន ដោយឈរលើអភិក្រម "**ពង្រឹង និងការរៀបចំផ្ទះរបស់ខ្លួនឱ្យរៀបរយ**"។

### ខ. តួនាទី និងភារកិច្ច

**ក.យ.ផ.គ.** ប្រចាំក្រសួង ស្ថាប័នសាមី ត្រូវមានតួនាទី និងភារកិច្ច ដូចតទៅ៖

- សម្របសម្រួលរួម និងណែនាំដល់អង្គភាពចំណុះក្រសួង ស្ថាប័ន លើកិច្ចការងារតាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តយុទ្ធសាស្ត្រ, ផែនការអភិវឌ្ឍន៍ និងគោលនយោបាយនានា ក្រោមសមត្ថកិច្ចរបស់ខ្លួន

- ចូលរួមរៀបចំ និងអនុវត្តក្របខ័ណ្ឌតាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តយុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១ និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០២៤-២០២៨
- ដឹកនាំ និងជំរុញការអនុវត្តយុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១, ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ, យុទ្ធសាស្ត្រ និងគោលនយោបាយនានា ក្រោមសមត្ថកិច្ចរបស់ខ្លួន
- ដឹកនាំ រៀបចំ អនុវត្ត និងតាមដានសូចនាករសមិទ្ធកម្មគន្លឹះ ដែលបានកំណត់ក្នុងក្របខ័ណ្ឌតាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តយុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១, ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ, យុទ្ធសាស្ត្រ និងគោលនយោបាយនានា ក្រោមសមត្ថកិច្ចរបស់ខ្លួន
- ដឹកនាំ រៀបចំ និងផ្តល់សុពលភាពលើក្របខ័ណ្ឌតាមដាន ត្រួតពិនិត្យ និងវាយតម្លៃរបស់ក្រសួង ស្ថាប័ន ដែលរៀបចំឡើងដោយអនុលោមតាមក្របខ័ណ្ឌតាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តយុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១។
- រៀបចំកម្មវិធីបណ្តុះបណ្តាល និងសិក្ខាសាលាពាក់ព័ន្ធលើផ្នែកតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ ក្រោមសមត្ថកិច្ចរបស់ខ្លួន
- ចូលរួម និងសហការក្នុងការវាយតម្លៃការអនុវត្តសូចនាករសមិទ្ធកម្មគន្លឹះ ក្រោមសមត្ថកិច្ចរបស់ខ្លួន
- ធ្វើសុពលភាពទិន្នន័យស្តីពីវឌ្ឍនភាពនៃការអនុវត្តសូចនាករសមិទ្ធកម្មគន្លឹះ ក្រោមសមត្ថកិច្ចរបស់ខ្លួន
- ដឹកនាំ និងចូលរួមក្នុងការរៀបចំប្រព័ន្ធព័ត៌មានវិទ្យានៃការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃប្រចាំក្រសួង ស្ថាប័នរបស់ខ្លួន
- រៀបចំ បូកសរុប និងផ្តល់របាយការណ៍វឌ្ឍនភាពការងារ សមិទ្ធកម្ម និងបញ្ហាប្រឈមនៃការអនុវត្តកិច្ចការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ ក្រោមសមត្ថកិច្ចរបស់ខ្លួន
- អនុវត្តកិច្ចការផ្សេងៗទៀតតាមការប្រគល់ពីប្រធាន **គ.យ.ផ.គ.** ពាក់ព័ន្ធនឹងកិច្ចការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តយុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១ និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ, យុទ្ធសាស្ត្រ និងគោលនយោបាយនានា។

ទទួលបានសារាចរនេះ ទីស្តីការគណៈរដ្ឋមន្ត្រី គណៈកម្មាធិការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តយុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១ (គ.យ.ប.) ក្រសួងផែនការ និង គ្រប់ក្រសួង ស្ថាប័ន ត្រូវអនុវត្តឱ្យមានប្រសិទ្ធភាព និងដោយស្មារតីទទួលខុសត្រូវខ្ពស់។

ថ្ងៃព្រហស្បតិ៍ [illegible] ឆ្នាំរោង ឆស័ក ព.ស.២៥៦៨

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៤ ខែកក្កដា ឆ្នាំ២០២៤

**នាយករដ្ឋមន្ត្រី**

**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត**

**កន្លែងទទួល៖**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័ន
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ